# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១

## អ្នករាយកាណ៍ពិសេស អ.ស.ប ស្តីពី ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ជំរុញអាជ្ញាធរឲ្យបញ្ឈប់ធ្វើសេចក្តីព្រាងច្បាប់ NGO

ហ្សឺណែវ៖ លោក **សុរិយា ស៊ូប៊ីឌី** អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា បានជំរុញអាជ្ញាធរកម្ពុជាឲ្យពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ នូវសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយសម្តែងនូវក្តីកង្វល់ថា "សេចក្តីព្រាងច្បាប់នេះអាចបង្អាក់ដល់ការងារស្របច្បាប់របស់អង្គការមិនមែនរដ្ឋាភិបាលនានានៅក្នុងប្រទេសនេះ។"

លោក **ស៊ូប៊ីឌី** បានថ្លែងនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ* របស់លោកស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្សថា "រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាពុំគួរបន្តធ្វើសេចក្តីព្រាងច្បាប់ NGOs នេះ នៅក្នុងបែបផែនបច្ចុប្បន្ននេះនោះទេ"។ "ប្រាកដណាស់ ក្នុងឋានៈជាប្រទេសអធិបតេយ្យ កម្ពុជាមានសិទ្ធិគ្រប់គ្រាន់ដើម្បីនឹងអនុម័តច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែការសម្រេចចិត្តតាក់តែងច្បាប់មួយឡើង ដើម្បីធ្វើនិយ័តកម្ម NGOs និងសមាគម គឺជាការផ្តួចផ្តើមដ៏សំខាន់មួយ ដែលត្រូវការឲ្យមានការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ ដោយសារតែវាមានផលវិបាកជាប់ទាក់ទិនគ្នារយៈពេលវែងទៅលើការអភិវឌ្ឍន៍នៃសង្គមកម្ពុជា និងជារួម គឺការអភិវឌ្ឍន៍ប្រទេសកម្ពុជាផ្ទាល់តែម្តង។"

អ្នកជំនាញការ អ.ស.ប រូបនេះ បានទាញចំណាប់អារម្មណ៍ជាពិសេសចំពោះតថភាពថា អង្គការសង្គមស៊ីវិលជាច្រើននៅក្នុងប្រទេសកម្ពុជា បាននឹងកំពុងដើរតួនាទីបំពេញបន្ថែមលើតួនាទីរបស់រដ្ឋក្នុងការជួយ ឬផ្តល់សេវាសង្គមកិច្ចសំខាន់ៗ ក្នុងវិស័យអប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ អនាម័យ សុខមាលភាពសង្គម និងការការពារធនធានធម្មជាតិ និងបរិស្ថាន។

រួមគ្នាជាមួយនឹង **លោក ម៉ៃណា គីអៃ** អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម និងលោកស្រី **ម៉ាហ្គារិត សឺខេជយ៉ា** អ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍អ្នកការពារសិទ្ធិមនុស្ស លោក **ស៊ូប៊ីឌី** ក៏បានជំរុញរាជរដ្ឋាភិបាលឲ្យពិចារណាយ៉ាងហ្មត់ចត់នូវកង្វល់នានា ដែលត្រូវបានលើកឡើងនៅកំឡុងដំណើរការពិគ្រោះយោបល់មុនពេលអនុម័តច្បាប់នេះ ជាពិសេសលក្ខខណ្ឌតម្រូវដ៏ស្មុគស្មាញនានាសម្រាប់ការចុះបញ្ជី និងកង្វះខាតនៃលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ថាតើពាក្យសុំចុះបញ្ជីបែបណាដែលនឹងត្រូវយកទៅពិចារណា។

នៅក្នុងរបាយការណ៍របស់លោក លោក **ស៊ូប៊ីឌី** ទទួលស្គាល់ថា ស្ថានការណ៍សិទ្ធិមនុស្សជារួមនៅកម្ពុជាមានការរីកចំរើន ជាពិសេសចំពោះការអនុម័តច្បាប់សំខាន់ៗមួយចំនួន។ លោកក៏បានកត់សំគាល់ផងដែរថា រាជរដ្ឋាភិបាលបានពន្លឿនកម្មវិធីនីតិកម្មរបស់ខ្លួន ដែលរៀបចំឡើងដើម្បីអនុវត្ត ជាអាទិ៍

អនុសាសន៍ចម្បងៗ ដែលលោកបានផ្តល់ទាក់ទងនឹងវិស័យតុលាការ នៅក្នុងរបាយការណ៍របស់លោក កាលពីឆ្នាំមុន។

ទោះបីជាដូច្នោះក៏ដោយ អ្នករាយការណ៍ពិសេសបានគូសបញ្ជាក់ថា នៅតែមាន "ការងារជាច្រើន អនេកទៀត ដែលត្រូវធ្វើដើម្បីពង្រឹងនីតិរដ្ឋ ពន្លឿនដំណើរការប្រជាធិបតេយ្យូបនីយកម្ម និងបង្កើនសមត្ថភាព សភាក្នុងការត្រួតពិនិត្យគណនីភាពរបស់អង្គនីតិប្រតិបត្តិ។"

លោកមានមតិផ្ទាល់ខ្លួនថា ទោះជាមានការរីកចំរើនគួរឲ្យកោតសរសើរ ដែលកម្ពុជាសម្រេចបានក្នុង ការចងក្រងក្របខណ្ឌអនុវត្តន៍របស់សភាក្នុងរយៈពេលដ៏ខ្លីមួយក៏ដោយ "ក៏នៅមានឧបស័គ្គមួយចំនួនក្នុងការ បំពេញការងាររបស់សភាជាទូទៅ ហើយជាពិសេសនោះគឺរដ្ឋសភាតែម្តង" និងជាពិសេសការងារ ដែលទាក់ ទិននឹងការប្រើប្រាស់សេរីភាពនៃការបញ្ចេញមតិរបស់សមាជិកសភា និងការបំពេញមុខងារជាតំណាងរាស្ត្រ ដ៏មានប្រសិទ្ធិភាពរបស់សមាជិកសភាដែលមកពីគណបក្សជំទាស់នានា។

(*)របាយការណ៍របស់អ្នករាយការណ៍ពិសេស៖

http://www2.ohchr.org/english/bodies/hrcouncil/docs/18session/A-HRC-18-46_en.pdf

**ចប់**

*លោក **សុរិយា ប្រាសាទ ស៊ូប៊ែឌី** ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប*
*តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០០៩ ។*
បច្ចុប្បន្នលោក*គឺជាសាស្ត្រាចារ្យនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស ។*

*គេហទំព័រ OHCHR ការិយាល័យប្រចាំកម្ពុជា៖*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*
*លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ៖ http://www2.ohchr.org/english/law/index.htm#core*
*សម្រាប់ព័ត៌មានបន្ថែម និង**សំណើរព័ត៌មាន** សូមទំនាក់ទំនង កញ្ញា Maureen Teo (Tel: + 41 22 928 9632 / email: mteo@ohchr.org).*

សម្រាប់**សំណើរព័ត៌មាន** ទាក់ទងនឹងអ្នកជំនាញការឯករាជ្យ អ.ស.ប៖
សូមទាក់ទង Xabier Celaya, ផ្នែកព័ត៌មានរបស់ការិយាល័យ OHCHR (+ 41 22 917 9383 / xcelaya@ohchr.org)

**សម្រាប់សិទ្ធិមនុស្ស អ.ស.ប សូមភ្ជាប់ទំនាក់ទំនងជាមួយយើងតាមរយៈ៖**
http://www.facebook.com/unitednationshumanrights
https://twitter.com/unrightswire

PRESS RELEASE

28 September 2011

UN Special Rapporteur on Cambodia urges authorities to stop the current draft NGO law

GENEVA – The United Nations Special Rapporteur on the situation of human rights in Cambodia, Surya P. Subedi, urged the Cambodian authorities to carefully review the current draft Law on Associations and Non-Governmental Organisations, expressing concern that "it may hamper the legitimate work of NGOs in the country."

"The Government of Cambodia should not proceed with the draft NGO law in its present form," Mr. Subedi said presenting his annual report* on the situation of human rights in Cambodia to the UN Human Rights Council. "Of course, as a sovereign country, Cambodia is entitled to enact a law on NGOs, but the decision to adopt a law to regulate NGOs and associations is a critical initiative which requires careful attention, given its long-term implications for the development of Cambodian society - and in turn the country – itself."

The UN expert drew special attention to the fact that many of the civil society organizations in Cambodia have been playing a complementary role to that of the State in helping or delivering key social services in the areas of education, health, rural development, sanitation, social welfare and the protection of natural resources and the environment.

Together with the UN Special Rapporteurs on the rights to freedom of peaceful assembly and of association, Mr. Maina Kiai, and on the situation of human rights defenders, Ms. Margaret Sekaggya, he also urged the Government to take fully on board the concerns raised during the consultation process before enacting the law, especially the onerous requirements for registration and the lack of clear criteria on which registration applications will be considered.

In his report, Mr. Subedi acknowledges that the overall situation of human rights had improved over the years in Cambodia, especially with the enactment of a number of key legislations. He also notes that the Government has sped up its legislative programme designed to implement, among other things, the key recommendations he made relating to the judiciary in his report last year.

However, the Special Rapporteur underscored that there still was "a great deal of work to be done to strengthen the rule of law, to accelerate the process of democratisation and to enhance the capacity of parliament to hold executive to account."

In his view, despite encouraging progress made by the country in developing parliamentary practices within a relatively short period of time, "there remains a number of shortcomings in the workings of Parliament in general and the National Assembly in particular," and especially those relating to the exercise of freedom of speech by members of parliament and effective representation of their constituents by those belonging to the opposition political parties.